ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឈឈឈ

តុលាការកំពូល

ឈឈ

សភាផ្នែករដ្ឋប្បវេណី

សាលាឧទ្ធរណ៍រដ្ឋប្បវេណី

លេខ : ៦៨

ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ១៩៩៩

-----

សាលដីកា

លេខ : (២២៣)

ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១ _ឯកឧត្តម ឌិត មុន្ទី ប្រធាន

២ _លោក ប៉ែន ស៊ុន ចៅក្រម

៣ _លោក ទៀល មួន ចៅក្រមរបាយការណ៏

៤ _លោក ជីវ កេង ចៅក្រម

៥ _លោក ស៊ុន ឌឹម ចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៨០១ ចុះថ្ងៃទី ២២.១២.៩៨ នៃសាលាឧទ្ធរណ៍រដ្ឋប្បវេណីលេខ ២៩៤ ចុះថ្ងៃទី ០៥.៥.៩៧ របស់សាលាឧទ្ធរណ៏ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ នាង ស៊ីន ហៅ សាយ ម៉ាន ភេទស្រី អាយុ ៥០ ឆ្នាំ ជាតិ ខ្មែរ របរធ្វើស្រែ លក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិវត្ត ឃុំ ស្រុក ខេត្ត ក្រចេះ ។ ឪពុកឈ្មោះ ហុង ជា "ស" ម្តាយឈ្មោះ តាយ គីម "ស" ។

និង តតិយជន ឈ្មោះ គិត សុខហេង ភេទស្រី អាយុ ៤១ឆ្នាំ ជាតិ ខ្មែរ របររក ស៊ី លក់ ដូរ ទីលំនៅសព្វថ្ងៃ ភូមិវត្ត ឃុំ ស្រុក ខេត្ត ក្រចេះ ។ តំណាងអោយឈ្មោះ ហាយ សេង "ជាប្តី" ។ "ជាម្ចាស់បណ្តឹងសាទុក្ខ" ដែលមានលោក សេង សឿ ជាមេធាវី ។

កម្មវត្ថុបណ្តឹង : ប្តឹងពីសូរិយោដីខេត្ត យកដីរបស់ខ្លួន ធ្វើប្លង់អោយអ្នកដទៃ

តាមបណ្តឹងសាទុក្ខលេខ ៤៣៨ ចុះថ្ងៃទី ២៣.១២.៩៨ របស់ឈ្មោះ នាង ស៊ីន និងបណ្តឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី ២៦.០១.៩៩ របស់ឈ្មោះ គិត សុខហេង "តំណាងអោយប្តីឈ្មោះ ហាយ សេង" ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ៨០១ ចុះថ្ងៃទី ២២.១២.៩៨ របស់សាលាឧទ្ធរណ៏លើចំនុច នៃសេចក្តីសំរេចទាំងមូល ។

បានឃើញឃុំទៀងនេះក៏បន្តធ្វើការនិងគិតផ្សេងទៀតលេខ ៦៨ ចុះថ្ងៃទី ១៥.៣.៥៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៣.៦.៥៥ ឈ្មោះ នាង ស៊ីន ហៅ សាយ ម៉ាន បានប្តឹងពីឈ្មោះ ស៊ាង ហុង ជាអនុប្រធាន សុរិយោដីខេត្តក្រចេះ ដែលបានយកដីរបស់ខ្លួនចេញប្លង់អោយអ្នកដទៃ ។

បានឃើញសាលក្រមលេខ ១២ ចុះថ្ងៃទី ០៦.៣.៥៧ របស់ តុលាការខេត្តក្រចេះ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១_ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ១៩៥៥ របស់ដើមចោទ មានលក្ខណៈសមស្រប តាមទំរង់ និង គតិច្បាប់ ។

២_ដីភូមិដែលមានក្បាល ៧ ម៉ែត ១០ម បណ្តោយ ២៧ ម៉ែត ១០ម ប្រគល់អោយដើមចោទគ្រប់គ្រង ធ្វើជាកម្មសិទ្ធិតទៅ តែទុកសិទ្ធិអោយចុងចោទ ឈ្មោះ ហាយ សេង មានសិទ្ធិដើរហើរទៅមកតាមដីឡូតិ៍ខាងខ្នងផ្ទះជាន់ក្រោមរបស់អ្នកស្រី នាង ស៊ីន រហូតតទៅ ។

៣_បង្គាប់អោយចុងចោទ ឈ្មោះ ហាយ សេង និង តំណាងសុរិយោដីខេត្តបង់ប្រាក់ប្រដាប់ក្តី ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង ចំនួន ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ចំនួន ២០០៛ ប្រាក់ស៊ើបអង្កេត ៥.០០០៛ បូករួម ៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទ បានបង់ទុករួចហើយ ហើយប្រាក់ស៊ើបអង្កេត ៥.០០០៛ ត្រូវចំណាយអស់ទៅអោយស៊ើបអង្កេត ។ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់អោយចុងចម្លើយបង់ប្រាក់ ៧.០០០៛ និង បង់ពន្ធសមាមាត្រ ចំនួន $\frac{១ \text{ គុណ } ៧.០០០.០០០}{១០០}$ : ៧០.០០០៛ បន្ថែមទៀត ហើយត្រូវដាក់ចូលថវិការជាតិចំនួន $\frac{៨០ \text{ គុណ } ៧០.០០០}{១០០}$ : ៥៦.០០០៛ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន $\frac{២០ \text{ គុណ } ៧០.០០០}{១០០}$ : ១៤.០០០៛ ប្រាក់នេះត្រូវបង្គាប់អោយដើមចោទបង់ទុកជាមុន ទើបបង្គាប់អោយចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

សាលក្រមនេះជំនុំជំរះជាសាធារណៈ នៅចំពោះមុខដើមចោទ និង ចុងចម្លើយ ឈ្មោះ ហាយ សេង និង លោក ជុំ ផុន តំណាងអោយ សុរិយោដីខេត្ត សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ រយៈពេលពីរខែ គិតចាប់ពីថ្ងៃនេះតទៅ ។

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីអនុវត្តសាលក្រម ស្ថាបន័មានសមត្ថកិច្ច កងកំលាំងប្រដាប់អាវុធអោយជួយអនុវត្តសាលក្រមនេះអោយបានសំរេច កាលបើមានសំណូមពរចាំបាច់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ ហាយ សេង ចុះថ្ងៃទី ២៣.៤.៥៧ ប្តឹងមិនសុខចិត្ត លើសេចក្តីសំរេច នៃ សាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៨០១ ចុះថ្ងៃទី ២២.១២.៩៨ ដែលមានខ្លឹមសារ និង សេចក្តីសំរេចដូចតទៅ :

១_ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៣.៤.៩៧ របស់ឈ្មោះ ហាយ សេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២_តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១២ ចុះថ្ងៃទី ០៦.៣.៩៧ របស់តុលាការខេត្តក្រចេះ ទុកជាបានការ ប៉ុន្តែលើកលែងចំនុចទី២ និង ពន្ធលមាមាត្រ ត្រូវកែប្រែជា ថ្មី ។

៣_ក.ប្រគល់ដីទំហំ DHD'C'GC អោយឈ្មោះ ហាយ សេង កាន់កាប់ និង គ្រប់គ្រងជាកម្មសិទ្ធិ នៅពេលដែល សាលដីកានេះចូលជាស្ថាពរ ។

ខ.ប្រគល់ដីទំហំ BCC'B'FB អោយឈ្មោះ នាង ស៊ីន កាន់កាប់និង គ្រប់គ្រង ជាកម្មសិទ្ធិ នៅពេលដែល សាលដីកានេះចូលជាស្ថាពរ ។

គ.ដីទំនាស់ទំហំ ABFB'A'EA ត្រូវទុកជាដីសំរាប់ប្រើប្រាស់រួម រវាង ឈ្មោះ នាង ស៊ីន , ហាយ សេង និង ផ្ទះខាងក្រោយ នៅពេលដែលសាលដីកានេះចូល ជាស្ថាពរ ។

ឃ.បង្គាប់អោយឈ្មោះ ហាយ សេង បង់ពន្ធលមាមាត្រ មួយភាគរយ លើ តំលៃដីទំនាស់ ទំហំ BCEC'B'FB ។

៤_សំរេចកាត់យកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួចហើយ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង ២.៥៥០៛ រដ្ឋាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីការកោះ ៥.០០០៛ និង ភាផ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៥_សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខឈ្មោះ នាង ស៊ីន កំបាំងមុខ ហាយ សេង និង ល៊ាង ហុង បើកផ្លូវតវ៉ា ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៣៨ ចុះថ្ងៃទី ២៣.១២.៩៨ របស់ឈ្មោះ នាងស៊ីន និង បណ្តឹងសាទុក្ខលេខ ២៥ ចុះថ្ងៃទី ២៦.០១.៩៩ របស់ឈ្មោះ គិត សុខហេង តំណាងអោយប្តី ឈ្មោះ ហាយ សេង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណារបស់ឈ្មោះ នាង ស៊ីន ចុះថ្ងៃទី ២៤.៤.៩៩ ។

បានឃើញសារណារបស់ឈ្មោះ គីក សុខហេង ចុះថ្ងៃទី ០៣.៦.៩៩ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :

_ បណ្តឹងសាទុក្ខរបស់ដើមចោទ និង តតីយជន ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយកពិនិត្យ ពិចារណា ។ សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តី



៧៧

មកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់តទៅ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ នាង ស៊ីន ជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

-ខ្លួនសុំទុកដីកៀនផ្ទះ ជាដីសាធារណៈ ព្រោះបើបិទផ្លូវខ្លួនគ្មានច្រកចេញចូលទេ ។ ព្រោះគ្មានច្រកផ្សេងទៀត ដើម្បីចេញចូល ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ គិត សុខហេង ខ្លួនទិញដីមានប្លង់ទាំងមូល ពេលខ្លួនទិញ ខ្លួនសួរគេ គ្រប់ជាន់ថ្នាក់ គ្មានទំនាស់ មានព្រំប្រទល់ត្រឹមត្រូវ ខ្លួនមិនព្រមចែកអោយគាត់ទេ បើមាននៅក្នុងប្លង់ម៉េច អោយអញ្ចឹងទៅ ហើយខ្លួនក៏មិនបានបិទផ្លូវ នោះដែរ ខ្លួនទិញដីនេះក្រោយគាត់មែន តែខ្លួនបានចាត់ដី និង កាប់ដើមស្វាយចោល តែគាត់មិនថាអីទេ ស្រាប់តែឆ្នាំ ១៩៩៨ ទើបគាត់ទៀមទារ ។ ខ្លួនសុំរក្សាប្លង់ អោយនៅដដែល ។

មេធាវីរបស់តតីយជន ធ្វើសេចក្ដីសន្និដ្ឋានថា :

-ដីនេះដើមឡើយ ជាផ្ទះរបស់ជនាញការវៀតណាមរស់នៅ ដល់ឆ្នាំ ១៩៨០ វៀតណាមចេញ ឈ្មោះ ប៊ូ សុផារ៉ាត់ ជាអ្នកគ្រប់គ្រងទាំងអស់ ហើយក៏លក់អោយកូនក្ដីខ្លួន ដោយមានប្លង់ត្រឹមត្រូវ ។ ឯឈ្មោះ នាង ស៊ីន ទិញពីឈ្មោះ អ៊ួង អែម ឯឈ្មោះ នេះ គ្រាន់តែជាអ្នកស្នាក់នៅ បណ្ដោះអាសន្នតែប៉ុណ្ណោះ ។ សុំតំកល់ប្លង់នេះតាមច្បាប់ ព្រោះប្លង់នេះត្រឹមត្រូវ ។ សុំអោយអ្នកស្រី ស៊ីន ទាមទារប្រាក់ពីឈ្មោះ អ៊ួង អែម វិញចុះ ។

-ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយដោះសារ របស់ដើមចោទ និង តតីយជន និង សេចក្ដីសន្និដ្ឋាន របស់មេធាវី តតីយជន ។

-ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-ឃើញថា បណ្ដឹងសាទុក្ខលេខ ៤៣៨ ចុះថ្ងៃទី ២៣.១២.៩៨ របស់អ្នកស្រី នាង ស៊ីន និង បណ្ដឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី ២៦.០១.៩៩ របស់អ្នកស្រី គិត សុខហេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

-ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំហំ BC6C'B' FB ទាំងមូល



៣៧

តាមប្តឹងបង្ហាញទីតាំងដី ចុះថ្ងៃទី ១៩.១២.៥៦ អោយទៅអ្នកស្រីនាង ស៊ីន នោះជាការត្រឹមត្រូវ ពីព្រោះថា :

.ដីមុខផ្ទះនេះ តាមលិខិតបញ្ជាក់ របស់លោកមេឃុំ ក្រចេះ និង លិខិតលោក ឌូ ភឿង ដីនេះជាដីដែលឪពុកលោក ប៊ូ សុផារ៉ាត បានកាន់កាប់ ដីកដីចាក់បំពេញព្រមទាំងរៀបចំ ប្រព័ន្ធលូបង្ហូរទឹកទៀតផង ហើយអ្នកនៅជាន់ខាងក្រោម មិនដែលទាមទារកម្មសិទ្ធិដីមុខផ្ទះនេះទេ ។

.តាមចម្លើយចុះថ្ងៃទី ១៣.៨.៥៦ លោក អ៊ឹង អែម ម្ចាស់ផ្ទះដើមដែលលក់អោយអ្នកស្រី នាង ស៊ីន ក៏ទទួលស្គាល់ដែរថា ឪពុកលោក ប៊ូ សុផារ៉ាត ជាអ្នកអាស្រ័យផល លើដំណាំ ដែលដុះលើដីនេះដែរ ។

-យល់ឃើញថា សាលដីការដ្ឋបូរេវណីលេខ ៨០១ ចុះថ្ងៃទី ២២.១២.៩៨ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខ គូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ២៩ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៩ របស់អ្នកស្រី គិត សុខហេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលបណ្តឹងសាទុក្ខលេខ ៤៣៨ ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ១៩៩៤ របស់អ្នកស្រី នាង ស៊ីន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈ សាលដីការដ្ឋបូរេវណីលេខ ៨០១ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៤-បង្វិលសំណុំរឿងរដ្ឋបូរេវណីលេខ ៦៨ ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៥-ដីបអ្នស្រប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលអ្នកស្រី នាង ស៊ីន បានបង់រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០៛ សរុប ១៦.០០០៛ បង្វិលប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០៛ ដែលអ្នកស្រី គិត សុខហេង បានបង់រួចហើយជូនអ្នកស្រីរូបនេះវិញ ។

៦-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ១៩៩៩ ។